Date: 15/03/2025 Vol. 1 Issue: 11 RF

ព្រឹត្តិបត្រព័ត៌មាន
NEWSLETTER

# ស្ពាតហ្វូនអេបៈ សត្វក្នុងដីនៅពាយព្យនៃប្រទេសកម្ពុជា

សត្វក្នុងដីនៅប្រទេសកម្ពុជា នីមានការសិក្សាស្រាវជ្រាវតិចតួចណាស់ប្រើប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍នៅលើសាកលលោក ជាពិសេសសត្វនៅក្នុងដីកសិកម្ម។ ក្រុមអ្នកស្រាវជ្រាវរបស់សាកលវិទ្យាល័យជាតិបាត់ដំបងបានទទួលហិរញ្ញបទានពី 'គម្រោងកែលម្អឧត្តមសិក្សា' (Higher Education Improvement Project – HEIP) ដើម្បីធ្វើការស្រាវជ្រាវអំពីសត្វល្អិតក្នុងដីនៅតំបន់ពាយព្យនៃប្រទេសកម្ពុជា ក្រោមអនុគម្រោងគម្រោង 'នវានុវត្តប្រព័ន្ធដាំដុះដំណាំដើម្បីបង្កើនអាហាររូបត្ថម្ភ និងប្រាក់ចំណូលនៅពាយព្យប្រទេសកម្ពុជា' (Innovative Farming systems for Improved Nutrient and Income in NW Cambodia – IFINI)។

សត្វក្នុងដីចំនួន ៦៨ លំដាប់នៃចំណាត់ថ្នាក់ដីត្រូវបានកំណត់អត្តសញ្ញាណ និងកត់ត្រាក្នុងសៀវភៅ និងស្ពានហ្វូនអេប។

ក្រុមការងាររបស់គម្រោង IFINI ៖

| | |
|---|---|
| បណ្ឌិត ស្រ៊ន ពៅ | លោក ហ៊ន សំអាត |
| លោក ប៉ុក បញ្ញា | កញ្ញា ឡូ ស្រីង៉ែត |
| លោក សៀវ សុវណ្ណា | លោក សល សីហា |
| លោក ឃិន សុផារី | លោក រឿន សុធា |




សត្វក្នុងដី ឬសារពាង្គកាយដែលរស់នៅក្នុងដី អាចរាប់បញ្ចូលទាំងភាវរស់អាចមើលឃើញដោយភ្នែកទទេ និងមិនអាចមើលឃើញដោយភ្នែកទទេ ដែលតម្រូវឲ្យមានមីក្រូទស្សន៍សម្រាប់ពង្រីកដើម្បីមើលឃើញរូបរាងវាច្បាស់។ គេបែងចែកសត្វក្នុងដីចេញជាបួនក្រុម ទៅតាមទំហំទទឹងខ្លួនរបស់វា រួមមានដូចខាងក្រោម៖

- **ទី1 ក្រុមសត្វមីក្រូ** (microfauna)៖ ទំហំទទឹងខ្លួន <0.1 mm (ឧ. ណេម៉ា តូដ ឬប្រូតូសូអា)
- **ទី2 ក្រុមសត្វមេសូ** (mesofauna)៖ ទំហំទទឹងខ្លួនចន្លោះពី 0.1 ទៅ 2.0 mm (ឧ. ចៃ ឬពីងពាង)
- **ទី3 ក្រុមសត្វម៉ាក្រូ** (macrofauna)៖ ទំហំទទឹងខ្លួនចន្លោះពី 2.0 mm ទៅ 20 mm (ឧ. កណ្ដៀរ ខ្ទួតដី ជន្លេន ម្រើមព្រះ ក្អែប ឬស្រមោច)
- **ទី4 ក្រុមសត្វមេហ្គា** (megafauna)៖ ទំហំទទឹងខ្លួន >20 mm (ឧ. ថ្លែន ឬពពួកសត្វល្អូនដទៃៗទៀត)។




## ប្រភេទទី 1: របៀបទាញយកកម្មវិធី

A. សម្រាប់ទូរស័ព្ទ Android (Samsung, Huawei, etc.)

1. **ស្វែងរក** Play Store
   - រកមើលរូបតំណាង **Play Store** .
   - ចុចលើPlay Store ដើម្បីបើក
2. **ស្វែងរកកម្មវិធី**
   - ចុច **search bar**
   - វាយឈ្មោះកម្មវិធី soil fauna
   - ចុចប៊ូតុង **search icon** ឬ "Enter".
3. **ទាញយកកម្មវិធី**
   - ស្វែងរក soil fauna app នៅក្នុងបញ្ជី.
   - ចុច **Install.**
   - រង់ចាំដើម្បីទាញយក.
4. **បើកកម្មវិធី**
   - នៅពេលដំឡើងរួច, ចុច **Open.**
   - ឬស្វែងរករូបតំណាងកម្មវិធីនៅលើអេក្រង់ ហើយចុចវា.

## ប្រភេទទី 2: របៀបប្រើកម្មវិធី

1. **បើកកម្មវិធី**
   - ចុចលើរូបតំណាងកម្មវិធីនៅលើអេក្រង់។
2. **ចាប់ផ្តើមប្រើប្រាស់**
   - ឥឡូវនេះអ្នកអាចស្វែងរក និងប្រើប្រាស់មុខងារនៃកម្មវិធី។
   - ឧទាហរណ៍ ស្វែងរកឈ្មោះសត្វដី ext.






នេះគឺជាការណែនាំសម្រាប់ការដំឡើងកម្មវិធីតាមរយៈ កូដ QR និងបន្ថែមវាទៅអេក្រង់ទូរស័ព្ទ Android និង iOS ។

📲 **សម្រាប់ប្រព័ន្ធប្រតិបត្តិការ Android**

☑ **ការប្រើប្រាស់ QR Code ដើម្បីចូលប្រើកម្មវិធី**

1. **បើកកាមេរ៉ាទូរសព្ទរបស់អ្នក** ឬប្រើកម្មវិធីស្កេន QR
2. **ស្កេនកូដ QR**
3. តំណភ្ជាប់នឹងលេចឡើង – ចុចប៊ូតុង **popup notification.**
4. កម្មវិធីនឹងបើកនៅក្នុងកម្មវិធីរុករក (browser) ជាធម្មតាក្នុង Chrome

📌 **ដាក់នៅលើ Home Screen (Web App)**

1. នៅពេលដែលកម្មវិធីបានបើកនៅក្នុង Chrome ចុច **សញ្ញា** ( ⋮ ) នៅខាងលើខាងស្តាំ.
2. ចុច **"Add to Home screen."**
3. សរសេរពាក្យ soil fauna
4. ចុច **"Add"** → រូបតំណាងនឹងបង្ហាញនៅលើអេក្រង់ដូចនឹងកម្មវិធីដទៃទៀត.

🍏 **សម្រាប់ប្រព័ន្ធប្រតិបត្តិការ iOS (iPhone/iPad)**

☑ **ការប្រើប្រាស់ QR Code ដើម្បីចូលប្រើកម្មវិធី**

1. បើកកម្មវិធី **Camera.**
2. ស្កេនកូដ QR.
3. ចុចលើតំណភ្ជាប់ដែលបង្ហាញ

### 📌 ដាក់នៅលើ Home Screen (Web App)

1. នៅពេលដែលកម្មវិធីបើកនៅក្នុង **Safari**, ចុច **Share button**
2. អូសចុះក្រោមហើយចុចលើ **"Add to Home Screen."**
3. សរសេរ soil fauna
4. ចុច **"Add."**
5. រូបតំណាងនឹងលេចឡើងនៅលើអេក្រង់របស់អ្នក។